ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ១២៤ "ខ" ក្រ៤
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤
សំណុំរឿងព្រហ្មទណ្ឌលេខ:៤៣៥៣
ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣
សំណុំរឿងស៊ើបសួរលេខ:៣២២៥
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ:៤៣០៣
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការ ជាអសាធារណៈ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤ នឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកចៅក្រម ជាចៅក្រមប្រឹក្សា
-លោកស្រីចៅក្រម ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌ លេខ:៤៣៥៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] រិទ្ធិស័ក្ត ភេទប្រុស កើតថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩(អាយុ១៤ឆ្នាំ) ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង សាសនា ព្រះពុទ្ធ មុខរបរ សិស្ស កម្រិតវប្បធម៌ ថ្នាក់ទី៧ អាសយដ្ឋានមុនពេលឃុំខ្លួន ស្នាក់នៅភូមិទ្រា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សាមិត្ត"វ" ម្ដាយឈ្មោះ [redacted] ស្រីណែត "វ" ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ(PJ) ដីកាបង្គាប់ឲ្យឃុំខ្លួន លេខ:៦៤៨៥"ខ"ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ លោកមេធាវី [redacted] ជាមេធាវីនៃក្រុមមេធាវី ច័ន្ទ វិចិត្រ មានការិយាល័យ ផ្ទះលេខ២៦AE$_0$ ផ្លូវលេខ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។



Scanned with CamScanner

-ជាប់ចោទពីបទ: ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខបុរីវ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១១ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២-ឈ្មោះ [redacted] វីន ភេទប្រុស កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៦(អាយុ១៧ឆ្នាំ) ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពត សាសនាព្រះពុទ្ធ មុខរបរ ជាងម៉ាស៊ីនត្រជាក់ កម្រិតវប្បធម៌ ថ្នាក់ទី៨ អាសយដ្ឋានមុនពេលឃុំខ្លួន បន្ទប់ជួលលេខ១២ ភូមិទ្រា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ[redacted] ជា “រ” ម្តាយឈ្មោះ[redacted] អឿ “រ” ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ(PJ) ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:៦៤៨៦“ខ”ង.ឃ.ង ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ លោកស្រីមេធាវី [redacted] (មេធាវីចាត់តាំង)។

៣-ឈ្មោះ[redacted] ចំរើន ភេទប្រុស កើតឆ្នាំ២០០៤(អាយុ១៨ឆ្នាំ) ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពត សាសនា ព្រះពុទ្ធ មុខរបរ កម្មកររោងចក្រ កម្រិតវប្បធម៌ ថ្នាក់ទី៤ អាសយដ្ឋានមុនពេលឃុំខ្លួន ស្នាក់នៅបន្ទប់ជួលលេខ១២ ភូមិទ្រា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម៉ារីន “រ” ម្តាយឈ្មោះ [redacted] ច្រាន់ “រ” ជានីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនមណ្ឌលអប់រំកែប្រែទី១(ម១) ដីកាបង្គាប់ឱ្យឃុំខ្លួន លេខ:៦៤៨៤“ខ”ង.ឃ.ង ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ លោកស្រីមេធាវី [redacted] ជាមេធាវីនៃក្រុមមេធាវី សិទ្ធិតំណាង និងការពារ មានការិយាល័យ ផ្ទះលេខB៩ ផ្លូវព្រៃស ភូមិ ព្រៃសកើត សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុច មុខបុរីវ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ[redacted] វង្សវឌ្ឍនា ភេទប្រុស កើតថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៥២៥ ផ្លូវលេខ៩៨K ភូមិព្រៃទា២ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណី៖ ឈ្មោះ[redacted] សារុត ភេទប្រុស អាយុ៤៤ឆ្នាំ មុខរបរ រត់កង់បី មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៥២៥ ផ្លូវលេខ៩៨K ភូមិព្រៃទា២ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



Scanned with CamScanner

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៨ និង ៣០នាទី មុនពេលកើតហេតុ មានមនុស្សមួយក្រុម ភាគី"ក" រួមមាន៖ ១.ឈ្មោះ [redacted] រិទ្ធិស័ក្ក ភេទប្រុស ២.ឈ្មោះ [redacted] វង្សវឌ្ឍនា ភេទប្រុស ៣.ឈ្មោះ រាត ភេទប្រុស ៤.ឈ្មោះ ហុង ភេទប្រុស និងបក្ខពួកចំនួន០៨នាក់ទៀត មិនស្គាល់ឈ្មោះនិងទីលំនៅ បានទាំគ្នាទៅឈប់ម៉ូតូអង្គុយជជែកគ្នាលេង នៅចំណុចមុខបុរីវ៉ូស ផ្លូវបេតុង ភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពេលនោះក៏មានភាគី"ខ" រួមមាន៖ ១-ឈ្មោះ [redacted] វីន ភេទប្រុស ជិះម៉ូតូ០១គ្រឿង ម៉ាកហុងដាវ៉េវ ពណ៌ស្វាយ ពាក់ផ្លាកលេខ ក្រុងកែប 1A-០៥៤៥ និង២-ឈ្មោះ [redacted] ចំរើន ភេទប្រុស ជិះម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1CK-០៣៧៣ ជិះកាត់មុខកន្លែងភាគី"ក" ហើយភាគី"ខ" បានសួរនាំភាគី"ក" ថាអង្គុយនៅកន្លែងនឹងធ្វើអ្វី ហើយក៏កើតមានទំនាស់ពាក្យសម្ដីគ្នាទៅវិញទៅមក ដោយភាគី"ក" ឈ្មោះ [redacted] រិទ្ធិស័ក្ក បានយកកាំបិតប៉ុងតោ ០១ដើម ដែលលាក់នៅគុម្ពស្មៅក្បែរនោះ ស្ទុះទៅកាប់លើភាគី"ខ" ទើបភាគី"ខ" បាននាំគ្នាជិះម៉ូតូរត់គេចខ្លួន ប៉ុន្តែក៏បានទៅបុកប៉ះត្រូវចំឈ្មោះ [redacted] វង្សវឌ្ឍនា បណ្ដាលឱ្យរងរបួសបាក់ជើងខាងឆ្វេង ហើយភាគី"ខ" បានដួលម៉ូតូនៅកន្លែងកើតហេតុ ពេលនោះភាគី"ក" បាននាំគ្នាយកកាំបិតប៉ុងតោកាប់ទៅលើម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1CK-០៣៧៣ ជារបស់ឈ្មោះ [redacted] ចំរើន បណ្ដាលឱ្យខូចខាតស្ទើរទាំងស្រុងបែកបាក់ក្បាលម៉ូតូខាងមុខ និងក្បាំងចំហៀងឆ្វេង និងបែកកុងទ័រ ព្រមទាំងដាច់របះផ្លាកលេខម៉ូតូ បន្ទាប់មកក៏មានបងប្អូនប្រជាពលរដ្ឋបានទូរស័ព្ទរាយការណ៍ប្រាប់សមត្ថកិច្ចក៏បានចុះមកដល់កន្លែងកើតហេតុ និងឃាត់ខ្លួនបានជនត្រូវចោទ ចំនួន០៣នាក់ រួមមានឈ្មោះ [redacted] រិទ្ធិស័ក្ក ជាភាគី"ក" ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] ចំរើន ដែលជាភាគី"ខ" ខាងលើរួមទាំងវត្ថុតាងយកមកសាកសួរចាត់ការតាមនីតិវិធីតែម្ដង ចំណែកឯបក្ខពួកភាគី"ក" ប៉ុន្មាននាក់ទៀតរត់គេចខ្លួនបាត់ និងឈ្មោះ [redacted] វង្សវឌ្ឍនា កំពុងព្យាបាលនៅមន្ទីរពេទ្យ។

-បានឃើញ របាយការណ៍លេខ:១៨៤/២៣ រ.ប.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ:៣២២១អ.យ.ណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ:៤២២១៣អ.យ.ណ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ:៥៣៩៦"ខ"ដ.ដ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិស័ក្ត បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ដំបូងខ្ញុំចេញពីសាលារៀន មកអង្គុយនិយាយគ្នាលេងនៅកន្លែងកើតហេតុ គឺមានគ្នាប្រហែល១២នាក់ ស្រាប់តែពេលនោះមានម៉ូតូចំនួន០២គ្រឿង បានជិះកាត់មុខពួកខ្ញុំ ដោយមានម៉ូតូសង់សេ១២៥ ស៊េរីឆ្នាំ២០២៣ ជិះដោយឈ្មោះ ចំរឿន និងម៉ូតូមួយគ្រឿងទៀតម៉ាកវ៉េវ។ ពេលនោះពួកគេជិះលឿន ហើយខ្ញុំក៏ស្រែកឲ្យថា "ម៉េចជិះលឿនម្លេះ" ពេលនោះស្រាប់តែម៉ូតូទាំងពីរគ្រឿងនោះបានជិះបកត្រឡប់មកវិញ ក៏រើសដុំថ្មគប់មកលើពួកខ្ញុំ តែគប់មិនត្រូវទេ ហើយពួកគេក៏ជិះម៉ូតូរត់ ហើយឈ្មោះ ចំរឿន ដែលជិះម៉ូតូសេ១២៥ បានបុកត្រូវពួកម៉ាកខ្ញុំ ឈ្មោះ [redacted] វង្សវឌ្ឍនា បណ្តាលឲ្យបាក់ជើងតែម្តង ហើយឈ្មោះ ចំរឿន ក៏បានដួលម៉ូតូតែម្តង។ នៅពេលកើតហេតុនោះ ខ្ញុំទទួលស្គាល់ថាបានកាន់ដុំថ្ម និងកាំបិតពិតមែន ប៉ុន្តែខ្ញុំមិនបានគប់ និងកាប់ទៅលើគេនោះទេ គឺក្រុមរបស់ខ្ញុំម្នាក់ ដែលខ្ញុំមិនស្គាល់ឈ្មោះ ជាអ្នកកាប់ទៅលើម៉ូតូគេ។ ចំពោះចម្លើយរបស់ខ្ញុំនៅសមត្ថកិច្ចខ្ញុំមិនទទួលស្គាល់ត្រង់ចំណុចថា ខ្ញុំបានយកកាំបិតលាក់ ប៉ុន្តែការពិតខ្ញុំមិនបានយកកាំបិតនោះទៅលាក់ទេ។ កាំបិតនោះជារបស់មិត្តខ្ញុំ ហើយខ្ញុំឃើញនៅក្នុងគុម្ពស្មៅ គឺខ្ញុំយកមកកាន់ក្នុងបំណងទុកការពារខ្លួន ដោយខ្ញុំមិនបានយកកាំបិតនោះទៅកាប់លើម៉ូតូគេទេ។ គ្នារបស់ខ្ញុំពេលនោះ គឺមាន១២នាក់ តែខ្ញុំស្គាល់តែ៣នាក់ប៉ុណ្ណោះ គឺមានឈ្មោះ [redacted] វង្សវឌ្ឍនា ភេទប្រុស អាយុ១៣ឆ្នាំ, ឈ្មោះ [redacted] ពុធីឆាត ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] លីហុង ភេទប្រុស អាយុ១៧ឆ្នាំ។ រូបខ្ញុំមិនមែនជាបងធំគេទេ ហើយក៏មិនធ្លាប់ប្រើប្រាស់គ្រឿងញៀនដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ចំរឿន បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៧ និង00នាទី ខ្ញុំបានជិះម៉ូតូម៉ាកC125 ឆ្នាំ២០២៣ ចំណែកឈ្មោះ [redacted] វីន ជិះម៉ូតូម៉ាក WAVE នាំគ្នាទៅរកទិញអីហូប នៅជិតវត្តត្រពាំងឈូក ពេលទិញរួចក៏បាននាំគ្នាត្រឡប់មកវិញ ជិះមកដល់ផ្លូវ បេតុងក្នុងភូមិកាកាប ក៏បានជួបមនុស្សប្រុសមួយក្រុម មានគ្នាប្រហែលជាង១០នាក់ កំពុងប្រឡែងគ្នា ពេលនោះឈ្មោះ [redacted] វីន ជិះម៉ូតូមុនខ្ញុំ តែគាត់ជិះយឺតៗ ឯខ្ញុំជិះលឿន ហួសទៅមុខមុន បន្ទាប់មកឈ្មោះ [redacted] វីន បានប្រាប់ខ្ញុំថាលឺសំឡេងស្រែកថាជិះលឿនម្ល៉េះ លឺដូច្នេះខ្ញុំក៏ជិះម៉ូតូត្រឡប់មកក្រោយវិញ ក្នុងបំណងមករកមើលអ្នកដែលស្រែកឲ្យខ្ញុំ ដោយពេលនោះខ្ញុំមិនទាន់បានយកដុំថ្មគប់ទៅលើគេមុនទេ គឺឈ្មោះ [redacted] វីន ជាអ្នកគប់ ហើយពេលនោះក្រុមរបស់ឈ្មោះ [redacted] រិទ្ធិស័ក ក៏បានបំបែកគ្នាជាពីរក្រុម ហើយខ្ញុំក៏បានជិះម៉ូតូរត់ ស្រាប់តែគ្នារបស់ក្រុមម្ខាងទៀតបានរត់មកកាក់ម៉ូតូរបស់ខ្ញុំ ទើបបណ្តាលឲ្យខ្ញុំបុកត្រូវបាក់ជើងតែម្តង ដោយខ្ញុំគ្មានចេតនាចង់បុកទេ។ ហើយខ្ញុំក៏ដួលម៉ូតូរួចខ្ញុំក៏ដើបរត់ ហើយក៏បានរើសដុំថ្មគប់ត្រូវគ្នារបស់ក្រុមគេម្នាក់ តែខ្ញុំមិនស្គាល់ឈ្មោះគេទេ ហើយខាងគេក៏គប់ត្រូវខ្ញុំវិញផងដែរគឺត្រូវត្រង់ចង្កេះ។ ចំពោះចម្លើយរបស់ខ្ញុំ ដែលបានឆ្លើយថា បានយកដុំថ្មគប់ត្រូវភាគីម្ខាងទៀត គឺជាចម្លើយត្រឹមត្រូវ ហើយដុំថ្មដែលខ្ញុំរើសគប់ត្រូវគេនោះគឺតូចដែរ។ ចំពោះឈ្មោះ [redacted] វីន គឺជិះម៉ូតូ



Scanned with CamScanner

មួយគ្រឿងទៀតម៉ាកវេវ បានត្រឡប់មកយកខ្ញុំហើយខ្ញុំក៏ឡើងជិះម៉ូតូជាមួយគាត់បានបន្តិចស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ [redacted] វីន តែម្តង។ ចំពោះភាគីក្រុមម្ខាងទៀតនោះ ខ្ញុំពុំដែលស្គាល់ទេ រីឯខាងខ្ញុំមានតែពីរនាក់ប៉ុណ្ណោះ គឺរូបខ្ញុំ និងឈ្មោះ [redacted] វីន។ ចំពោះម៉ូតូដែលត្រូវបានភាគីម្ខាងទៀតកាប់បណ្តាលឱ្យខូចខាតនោះ គឺជាម៉ូតូរបស់ខ្ញុំ ហើយអ្នកដែលកាប់ម៉ូតូខ្ញុំ គឺឈ្មោះ [redacted] រិទ្ធិស័ក្តិ។

-ជនជាប់ចោទឈ្មោះ [redacted] វីន បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ គឺខ្ញុំជាអ្នកស្តាប់ឮគេស្រែកថា "ជិះទៅណាលឿនម្លេះបង" ហើយខ្ញុំក៏ប្រាប់ទៅឈ្មោះ [redacted] ចំរើន ហើយឈ្មោះ [redacted] ចំរើន ក៏បានជិះបកក្រោយហើយខ្ញុំពិតជាបានរើសដុំថ្ម គប់ទៅលើភាគម្ខាងទៀត ចំនួនមួយដុំថ្ម តែមិនត្រូវអ្នកណាទេ ហើយពួកគេក៏មិនបានគប់ត្រូវខ្ញុំវិញដែរ រួចខ្ញុំក៏ជិះម៉ូតូចេញតែពេលខ្ញុំងាកមើលក្រោយឃើញម៉ូតូដួល ពេលនោះខ្ញុំឃើញក្រុមរបស់ឈ្មោះ [redacted] រិទ្ធិស័ក្តិ បានកាប់ម៉ូតូរបស់ឈ្មោះ [redacted] ចំរើន ហើយឈ្មោះ [redacted] ចំរើន កំពង់គប់គ្នាជាមួយឈ្មោះ [redacted] រិទ្ធិស័ក្តិ រួចឈ្មោះ កែវ ចំរើន បានបក់ដៃហៅខ្ញុំឱ្យមកវិញ ខ្ញុំក៏ជិះម៉ូតូបកមកវិញក្នុងបំណងមកជួយរំដោះគ្នាដោយឈ្មោះ [redacted] ចំរើន បានឡើងជិះម៉ូតូមកជាមួយខ្ញុំ រីឯម៉ូតូរបស់ឈ្មោះ [redacted] ចំរើន គឺនៅកន្លែងកើតហេតុពេលខ្ញុំ និងឈ្មោះ ចំរើន ជិះចេញបានបន្តិចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ ឯចំណែកអ្នកផ្សេងបានរត់គេចខ្លួនអស់ហើយពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំ ដកហូតម៉ូតូម៉ាក Wave ពណ៌ការ៉ុត សេរីឆ្នាំ២០១៦ មិនចាំស្លាកលេខ និងលុយចំនួន៥០,០០០រៀល(ហាសិបម៉ឺនរៀល) ចំពោះម៉ូតូរបស់ខ្ញុំពុំមានខូចខាតអ្វីទេ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សារុធ បានឆ្លើយថា៖ រូបខ្ញុំត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] វង្សវឌ្ឍនា ដែលត្រូវជនល្មើសបានជិះម៉ូតូបំបុកបណ្តាលឱ្យបាក់ជើងខាងឆ្វេង ហើយមានអ្នកភូមិទូរសព្ទប្រាប់ ពេលខ្ញុំមកដល់កន្លែងកើតហេតុ ក៏ឃើញកូនខ្ញុំឈ្មោះ [redacted] វង្សវឌ្ឍនា រងរបួសបាក់ភ្លៅខាងឆ្វេង បន្ទាប់មកខ្ញុំក៏បានបញ្ជូនកូនទៅមន្ទីរពេទ្យលោកសង្ឃ ប៉ុន្តែខាងមន្ទីរពេទ្យគេមិនទទួលដោយសារកូនខ្ញុំជាអនីតិជន អាយុ១៣ឆ្នាំ រួចមន្ទីរពេទ្យក៏ឱ្យនាំកូនទៅព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផាវិញ។ កូនខ្ញុំបានសម្រាកព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផាចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ មន្ទីរពេទ្យក៏ឱ្យចេញមកផ្ទះ ប៉ុន្តែក្រោយពេលចេញពីមន្ទីរពេទ្យ ខ្ញុំបាននាំកូនទៅព្យាបាលនៅគ្លីនិកឯកជនបន្ត ពីព្រោះរបួសកូនខ្ញុំពុំទាន់បានជាសះស្បើយនៅឡើយទេ។ ក្នុងរឿងនេះខ្ញុំទាមទារសំណងថ្លៃព្យាបាលរបួស ចំនួន២,០០០,០០០(ម្ភៃលាន)រៀល និងសំណងជំងឺចិត្ត ចំនួន៤,០០០,០០០(បួនលាន)រៀល តែខ្ញុំមិនមានភស្តុតាងបញ្ជាក់អំពីថ្លៃព្យាបាល គ្មានវិក័យបត្រពេទ្យទេ តែត្រូវចំណាយថ្លៃព្យាបាលទិញថ្នាំជារៀងរាល់ថ្ងៃ។ ចំពោះជនល្មើសខ្ញុំមិនច្បាស់ថាអ្នកណាជាអ្នកបុកកូនខ្ញុំទេ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] វង្សវឌ្ឍនា បានឆ្លើយថា៖ នៅមុនពេលកើតហេតុ ថ្ងៃទី៨ ខែសីហា ឆ្នាំ ២០២៣ វេលាម៉ោង១៨ និង៤០នាទី ខ្លួនបានចេញពីរៀនជាមួយមិត្តភក្តិឈ្មោះ [redacted] ពុទ្ធីឆាត ជិះម៉ូតូមួយពីរនាក់ ដោយខ្លួនជាអ្នកបើកម៉ូតូ(ម៉ូតូជារបស់ខ្លួន) គោលបំណងត្រឡប់ទៅផ្ទះ ពេលចេញបានបន្តិចពួកខ្លួនក៏បានឈប់ទិញខ្មៅ នៅជិតកន្លែងកើតហេតុ ខ្លួននិងឈ្មោះ [redacted] ពុទ្ធីឆាត កំពុងអង្គុយលើម៉ូតូក៏ស្រាប់តែឮសម្លេង



Scanned with CamScanner

ស្រែកពីក្រោយ ដោយខ្លួនស្តាប់ពុំបានទេ និងមានមនុស្សអ្វីអរនៅកន្លែងនោះដែរ ហើយឃើញមនុស្សរត់ឈ្លុះរ ឃើញសភាពការណ៍មិនស្រួល ខ្លួនក៏បានចុះពីលើម៉ូតូរត់ទាំងពីរនាក់ នៅពេលដែលខ្លួនកំពុងរត់ក៏ស្រាប់តែមាន ឡានបើកមកពីក្រោយ រួចហើយខ្លួនក៏រត់ឱ្យផុតពីមុខឡាន ស្រាប់តែមានម៉ូតូ០២គ្រឿង បើកវ៉ាឡានហើយក៏បាន មកប៉ះខ្លួន ក៏ដើបរៀបរត់បន្តក៏ត្រូវម៉ូតូ០១គ្រឿងទៀតមកបុកខ្លួនចំជើងខាងឆ្វេងបណ្តាលឱ្យរងរបួស ចំណែកមិត្ត ភក្តិខ្លួនវាបានរត់ចេញ រួចរត់ឡើងម៉ូតូមិត្តភក្តិវាជិះចេញទៅបាត់ អ្នកដែលបុកខ្លួននោះ ខ្លួនពុំដែលស្គាល់ទេ ក្រោយ ពេលកើតហេតុឪពុកម្តាយខ្លួន បាននាំខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យ រឿងហេតុអ្វីផ្សេងទៀត ខ្លួនពុំបានដឹងទេ។

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា សុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរ ទុកជាបានការ និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ចំរឿន បានធ្វើសេចក្តីសន្និដ្ឋាន ការពារថា៖ កូនក្តីខ្ញុំបានឆ្លើយសារភាពទទួលស្គាល់កំហុស ប៉ុន្តែការដែលកូនក្តីខ្ញុំ ជិះទៅបុកជនរងគ្រោះ គឺមិន មានចេតនាទេ ដោយសារតែជិះគេចខ្លួនពីកាប់របស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិស័ក្ត បើមិនគេចទេអាចប៉ះពាល់ ដល់អាយុជីវិតមិនខាន ដូច្នេះសុំឱ្យតុលាការផ្តល់ស្ថានសំរាលទោសដល់កូនក្តីខ្ញុំ ដើម្បីបានកែប្រែខ្លួន និងសុំឱ្យ តុលាការពិចារណាអំពីសំណងដល់ជនរងគ្រោះ ផ្អែកលើភស្តុតាង។ និងសុំទាមទារសំណងថ្លៃម៉ូតូ ពីជនជាប់ចោទ ឈ្មោះ [redacted] រិទ្ធិស័ក្ត ដោយសារតែម៉ូតូនោះ គឺទិញបង់រំលស់ ហើយខ្ញុំនឹងដាក់ភស្តុតាងជូននៅពេលក្រោយ និងសុំ ឱ្យតុលាការកែប្រែបទចោទលើកូនក្តីខ្ញុំ មកជាបទ ហិង្សាដោយអចេតនាមានស្ថានទម្ងន់ទោសវិញ ព្រោះកូនក្តីខ្ញុំ មិនមានចេតនាប្រព្រឹត្តនោះទេ។

-លោកមេធាវី [redacted] ជាមេធាវីការពារឱ្យឈ្មោះ [redacted] រិទ្ធិស័ក្ត បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពេលសាកសួរឃើញថា កូនក្តីខ្ញុំបានឆ្លើយបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការ ហើយ រឿងនេះមិនមានភស្តុតាង និងសាក្សីណាដែលអាចបញ្ជាក់បានថាកូនក្តីខ្ញុំបានប្រព្រឹត្តឡើយ ដូច្នេះសុំឱ្យតុលាការ សម្រេចឱ្យកូនក្តីខ្ញុំ បានរួចផុតបទចោទ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារជនជាប់ចោទ ឈ្មោះ [redacted] វីន បានធ្វើសេចក្តីសន្និដ្ឋាន ការពារថា៖ ក្រោយពីបានស្តាប់ការសាកសួររួចមក ឃើញថា កូនក្តីខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាលនីតិវិធី ដោយទទួលស្គាល់កំហុសរបស់ខ្លួន ដូច្នេះសុំឱ្យតុលាការផ្តល់ស្ថានសម្រាលទោស ដោយសារកូនក្តីខ្ញុំទើបតែប្រព្រឹត្ត ជាលើកទី១ ហើយជាអនីតិជនអាយុ១៧ឆ្នាំ យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៤០, យោងមាត្រា១៦០ និងមាត្រា១៦៤ នៃក្រមព្រហ្មទណ្ឌ សុំឱ្យព្យួរទោសកូនក្តីនាងខ្ញុំ។

-ជនជាប់ចោទឈ្មោះ [redacted] ចំរឿន, ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ត បានសំណូមពរជាសម្តីចុង ក្រោយថា ពួកខ្លួនដឹងកំហុសហើយ សុំឱ្យតុលាការបន្ធូរបន្ថយទោស។

-ក្រោយពីបាន ស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបាន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបាន ស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបាន ស្តាប់ជនជាប់ចោទធ្វើសំណូមពរជាសម្តីចុងក្រោយ

-ក្រោយពីបាន ពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបាន ពិភាក្សាក្រុមប្រឹក្សា

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

១-កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៨ និង ៣០នាទី នៅចំណុចមុខបុរីវ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតជាមានបទល្មើស **ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ **មួន រិទ្ធិស័ក្ត** ភេទប្រុស អាយុ១៤ឆ្នាំ,ឈ្មោះ [redacted] **ចំរឿន** ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ [redacted] **វីន** ភេទប្រុស អាយុ១៧ឆ្នាំ បណ្តាលឲ្យជនរងគ្រោះឈ្មោះ [redacted] **វង្សវឌ្ឍនា** រងរបួសបាក់ជើងខាងឆ្វេង ចំណែកបក្ខពួកផ្សេងទៀត បានគេចខ្លួនបាត់អស់តែម្តង។

២-ជនជាប់ចោទឈ្មោះ [redacted] **រិទ្ធិស័ក្ត** បានឆ្លើយថា: នៅថ្ងៃកើតហេតុ ពេលខ្លួនចេញពីសាលារៀន ក៏មកអង្គុយនិយាយគ្នាលេងនៅកន្លែងកើតហេតុ មានគ្នាប្រហែល១២នាក់ ស្រាប់តែពេលនោះមានម៉ូតូចំនួន០២គ្រឿង បានជិះកាត់មុខពួកខ្លួន ដោយមានម៉ូតូសង់សេ១២៥ ស៊េរីឆ្នាំ២០២៣ ជិះដោយឈ្មោះ ចំរឿន និងម៉ូតូមួយគ្រឿងទៀតម៉ាកវ៉េវ។ ពេលនោះពួកគេជិះលឿន ហើយខ្លួនក៏ស្រែកឲ្យថា "ម៉េចជិះលឿនម្លេះ" ពេលនោះស្រាប់តែម៉ូតូទាំងពីរគ្រឿងនោះបានជិះបកត្រឡប់មកវិញ ក៏រើសដុំថ្មគប់មកលើពួកខ្លួនហើយពួកគេក៏ជិះម៉ូតូរត់ ស្រាប់តែឈ្មោះចំរឿន ដែលជិះម៉ូតូសេ១២៥ បានបុកត្រូវពួកម៉ាកខ្លួន ឈ្មោះ [redacted] **វង្សវឌ្ឍនា** បណ្តាលឲ្យបាក់ជើង ហើយឈ្មោះចំរឿន ក៏បានដួលម៉ូតូ ហើយក្រុមរបស់ខ្លួនម្នាក់ ដែលខ្លួនមិនស្គាល់ឈ្មោះ បានកាប់ទៅលើម៉ូតូគេ។ នៅពេលកើតហេតុនោះ ខ្លួនទទួលស្គាល់ថាបានកាន់ដុំថ្ម និងកាំបិតពិតមែន ប៉ុន្តែមិនបានគប់និងកាប់លើម៉ូតូរបស់គេទេ។ ចំពោះចម្លើយរបស់ខ្លួននៅសមត្ថកិច្ច ត្រង់ចំណុចថាខ្លួនបានយកកាំបិតលាក់មិនមែនជាការពិតទេ ការពិតខ្លួនមិនបានយកកាំបិតនោះទៅលាក់ទេ។ ក្នុងចំណោមគ្នារបស់ខ្លួនទាំងអស់១២នាក់នោះ ខ្លួនស្គាល់តែ៣នាក់ប៉ុណ្ណោះ គឺមានឈ្មោះ [redacted] **វង្សវឌ្ឍនា** ភេទប្រុស អាយុ១៣ឆ្នាំ, ឈ្មោះ [redacted] **ពុទ្ធីឆាត** ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ១៧ឆ្នាំ។ ខ្លួនមិនមែនជាបងធំគេទេ ហើយក៏មិនធ្លាប់ប្រើប្រាស់គ្រឿងញៀនដែរ ចំពោះកាំបិតប៉ុងតោមិនមែនជារបស់ខ្លួនទេ ពេលនោះខ្លួនឃើញកាំបិតនៅក្នុងគុម្ពស្មៅ ដោយឃើញសភាពវឹកវរ ខ្លួនក៏រើសកាំបិតនេះមកកាន់ដើម្បីការពារខ្លួន តែខ្លួនពុះទាន់បានកាប់ទៅលើអ្នកណាទេ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។



Scanned with CamScanner

៣-ជនជាប់ចោទឈ្មោះ [redacted] ចំរឿន បានឆ្លើយថា: នៅថ្ងៃកើតហេតុ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៧ និង00នាទី ខ្លួនបានជិះម៉ូតូម៉ាកC125 ឆ្នាំ២០២៣ ចំណែកឈ្មោះ [redacted] វីន ជិះម៉ូតូម៉ាក WAVE នាំគ្នាជិះមកពីហ្វូបអីវិញ មកដល់ផ្លូវបេតុងក្នុងភូមិកាកាប ក៏បានជួបមនុស្សប្រុសមួយក្រុម មានគ្នាប្រហែលជាង១០នាក់ ពេលនោះឈ្មោះ [redacted] វីន ជិះម៉ូតូយឺតៗ ខ្លួនក៏ជិះល្បឿនហួសទៅមុខមុន បន្ទាប់មកឈ្មោះ [redacted] វីន បានប្រាប់ខ្លួនថាលឺសំឡេងស្រែកថាជិះលឿនម្លេះ លឺដូច្នេះខ្លួនក៏ជិះម៉ូតូត្រឡប់មកក្រោយវិញ ក្នុងបំណងមករកមើលអ្នកដែលស្រែកឱ្យខ្លួន តែពេលនោះខ្លួនមិនទាន់បានយកដុំថ្មគប់ទៅលើគេមុនទេ គឺឈ្មោះ [redacted] វីន ជាអ្នកគប់។ ពេលនោះស្រាប់តែក្រុមរបស់ឈ្មោះ [redacted] រិទ្ធិស័ក ក៏បានបំបែកគ្នាជាពីរក្រុម ហើយខ្លួនក៏បានជិះម៉ូតូរត់ ស្រាប់តែគ្នារបស់ក្រុមម្ខាងទៀតបានរត់មកកាត់ម៉ូតូរបស់ខ្លួន ទើបបណ្តាលឱ្យបុកត្រូវបាក់ជើង តែខ្លួនគ្មានចេតនាចង់បុកទេ ខ្លួនក៏ដួលម៉ូតូរួចងើបរត់ ហើយក៏បានរើសដុំថ្មគប់ត្រូវគ្នារបស់ក្រុមគេម្នាក់ តែមិនស្គាល់ឈ្មោះគេទេ ហើយខាងគេក៏គប់ត្រូវខ្លួនវិញផងដែរគឺត្រូវត្រង់ចង្កេះ។ ចំពោះឈ្មោះ [redacted] វីន គឺជិះម៉ូតូមួយគ្រឿងទៀតម៉ាកវេវ បានត្រឡប់មកយកខ្លួន ហើយខ្លួនក៏ឡើងជិះម៉ូតូជាមួយគាត់បានបន្តិច ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ ចំពោះអ្នកដែលកាប់ម៉ូតូរបស់ខ្លួន គឺឈ្មោះ [redacted] រិទ្ធិស័ក្ត។

៤-ជនជាប់ចោទឈ្មោះ [redacted] វីន បានឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្លួនជាអ្នកស្តាប់ឮគេស្រែកថា"ជិះទៅណាលឿនម្លេះបង" ហើយខ្លួនក៏ប្រាប់ទៅឈ្មោះ [redacted] ចំរឿន ហើយឈ្មោះ [redacted] ចំរឿន ក៏បានជិះបកក្រោយ។ ខ្លួនពិតជាបានរើសដុំថ្ម គប់ទៅលើភាគម្ខាងទៀត ចំនួនមួយដុំថ្ម តែមិនត្រូវអ្នកណាទេ ហើយពួកគេក៏មិនបានគប់ត្រូវខ្លួនវិញដែរ រួចខ្លួនក៏ជិះម៉ូតូចេញ តែពេលខ្លួនងាកមើលក្រោយ ឃើញម៉ូតូដួល ពេលនោះឃើញក្រុមរបស់ឈ្មោះ [redacted] រិទ្ធិស័ក្ត បានកាប់ម៉ូតូរបស់ឈ្មោះ [redacted] ចំរឿន ហើយឈ្មោះ [redacted] ចំរឿន កំពង់គប់គ្នាជាមួយឈ្មោះ [redacted] រិទ្ធិស័ក្ត រួចឈ្មោះ [redacted] ចំរឿន បានបក់ដៃហៅខ្លួនឱ្យមកវិញ ខ្លួនក៏ជិះម៉ូតូបកមកក្រោយមកជួយរំដោះគ្នា ពេលខ្លួន និងឈ្មោះ ចំរឿន ជិះចេញបានបន្តិចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។

៥-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សារុធ បានឆ្លើយថា៖ ខ្លួនត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] វង្សវឌ្ឍនា ដែលត្រូវជនល្មើសបានជិះម៉ូតូបំបុកបណ្តាលឱ្យបាក់ជើងខាងឆ្វេង ហើយមានអ្នកភូមិទូរស័ព្ទប្រាប់ ពេលខ្លួនមកដល់កន្លែងកើតហេតុ ក៏ឃើញកូនរបស់ខ្លួន ឈ្មោះ [redacted] វង្សវឌ្ឍនា រងរបួសបាក់ភ្លៅខាងឆ្វេង បន្ទាប់មកខ្លួនក៏បានបញ្ជូនកូនទៅមន្ទីរពេទ្យលោកសង្ឃ ប៉ុន្តែខាងមន្ទីរពេទ្យគេមិនទទួលដោយសារកូនខ្លួនជាអនីតិជនអាយុ១៣ឆ្នាំ រួចមន្ទីរពេទ្យក៏ឱ្យនាំកូនទៅព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផាវិញ។ កូនខ្លួនបានសម្រាកព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផា ចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ មន្ទីរពេទ្យក៏ឱ្យចេញមកផ្ទះ ប៉ុន្តែក្រោយពេលចេញពីមន្ទីរពេទ្យ ខ្លួនបាននាំកូនទៅព្យាបាលនៅគ្លីនិកឯកជនបន្ត ពីព្រោះរបួសកូនពុំទាន់បានជាសះស្បើយនៅឡើយទេ។ ក្នុងរឿងនេះ សុំទាមទារសំណងថ្លៃព្យាបាលរបួស ចំនួន២,០០០,០០០(ម្ភៃលាន)រៀល និងសំណងជំងឺចិត្ត ចំនួន៤,000,000(បួនលាន)រៀល។

៦-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចំរឿន, ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ត មានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ជនរងគ្រោះ ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និង



Scanned with CamScanner

វត្ថុតាងដែលបានដកហូតបានពីជនជាប់ចោទ អាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ចំរឿន និងជនជាប់ចោទឈ្មោះ [redacted] វីន ពិតជាបានធ្វើសកម្មភាព យកដុំថ្មគប់ទៅលើភាគីម្ខាងទៀត និងហើយជនជាប់ចោទឈ្មោះ [redacted] ចំរឿន បានជិះម៉ូតូបុកត្រូវជនរងគ្រោះឈ្មោះ [redacted] វង្សវឌ្ឍនា បណ្តាលឱ្យរងរបួសបាក់ជើងខាងឆ្វេង ចំណែកជនជាប់ចោទឈ្មោះ [redacted] រិទ្ធិស័ក្ក បានធ្វើសកម្មភាពយកកាំបិតប៉ុងតោ ដេញកាប់ទៅលើភាគីដែលមានជំលោះជាមួយក្រុមខ្លួន និងបានកាប់ទៅលើម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ ១CK-០៣៧៣ ជារបស់ឈ្មោះ [redacted] ចំរឿន បណ្តាលឱ្យខូចខាតស្ទើរទាំងស្រុង ប្រាកដមែន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចំរឿន និងឈ្មោះ [redacted] វីន មានចេតនាទុច្ចរិត ដែលបានធ្វើសកម្មភាពយកដុំថ្មគប់ទៅលើភាគីជំលោះម្ខាងទៀត និងជិះម៉ូតូបុកត្រូវជនរងគ្រោះឈ្មោះ [redacted] វង្សវឌ្ឍនា បណ្តាលឱ្យរងរបួសបាក់ជើងខាងឆ្វេង គឺជាបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់បញ្ញត្តិថាជាបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិស័ក្ក មានចេតនាទុច្ចរិត បានធ្វើសកម្មភាពយកកាំបិតប៉ុងតោកាប់បំផ្លាញម៉ូតូរបស់ឈ្មោះ [redacted] ចំរឿន បណ្តាលឱ្យខូចខាត និងដេញកាប់ទៅលើភាគីដែលមានជំលោះជាមួយក្រុមខ្លួន គឺជាបទល្មើសព្រហ្មទណ្ឌដែលច្បាប់បញ្ញត្តិថាជាបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស**។

៩-ជនជាប់ចោទឈ្មោះ [redacted] ចំរឿន, ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ក ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្ត ជននេះមានសមត្ថភាព លទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន ចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១០-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចំរឿន, ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ក បានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទទាំងនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តនេះ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ បំពានដល់នីត្យានុកូលភាពសង្គម និងបំពានលើមាត្រា៤១១ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

១១-មានភស្តុតាង និងមានពិរុទ្ធភាព ដាក់បន្ទុកគ្រប់គ្រាន់លើ៖

១១-១-ឈ្មោះ [redacted] ចំរឿន ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ [redacted] វីន ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខបុរីរ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

១១-២-ឈ្មោះ [redacted] រិទ្ធិស័ក្ក ភេទប្រុស អាយុ១៨ឆ្នាំ ពីបទ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបុរីរ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១១ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១២-ជនជាប់ចោទឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ត ពេលដែលពួកគេប្រព្រឹត្តបទល្មើស ទើបតែមានអាយុ១៧ឆ្នាំ និងអាយុ១៤ឆ្នាំ ហើយជនជាប់ចោទទាំងនេះ មានកម្រិតវប្បធម៌ទាប ស្ថិតក្នុងគ្រួសារក្រីក្រ តាមជីវប្រវត្តិកន្លងមក ពួកគេពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការលើកយកមកពិចារណាក្នុងការផ្តល់ស្ថានសម្រាល និងព្យួរទោស ដើម្បីផ្តល់ឱកាសឱ្យជននេះបានកែប្រែខ្លួនឡើងវិញ និងពិចារណាអំពីការអនុវត្តទោសតាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចំរឿន មានកម្រិតវប្បធម៌ទាប ស្ថិតក្នុងគ្រួសារក្រីក្រ តាមជីវប្រវត្តិកន្លងមកពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការលើកយកមកពិចារណាក្នុងការផ្តល់ស្ថានសម្រាល និងព្យួរទោស ដើម្បីផ្តល់ឱកាសឱ្យជននេះបានកែប្រែខ្លួនឡើងវិញ។

១៣-វត្ថុចាប់យក៖

១៣-១-ដកហូតបានពីឈ្មោះ [redacted] ចំរឿន មានម៉ូតូចំនួន០១គ្រឿង ម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1KC-0373 (មិនប្រក្រតី) ខូចខាតក្បាំងខាងមុខ ក្បាំងចំហៀង កុងទ័រ ស្តុបខាងក្រោយ និងខូចខាតផ្លាកលេខ គប្បីតុលាការសម្រេចប្រគល់ឱ្យឈ្មោះ [redacted] ចំរឿន វិញ។

១៣-២-ដកហូតបានពីឈ្មោះ [redacted] វីន មានម៉ូតូចំនួន០១គ្រឿង ម៉ាក HONDA WAVE C100 ពណ៌ក្រហម ផ្លាកលេខ ក្រុងកែប 1A-0545 (មិនប្រក្រតី) គប្បីតុលាការសម្រេចប្រគល់ឱ្យឈ្មោះ [redacted] វីន វិញ។

១៣-៣-ដកហូតបានពីឈ្មោះ [redacted] រិទ្ធិស័ក្ត រួមមាន៖

(១)-ម៉ូតូ០១គ្រឿង ម៉ាកHONDA DREAM C125 ពណ៌ខ្មៅ ផ្លាកលេខ តាកែវ 1H-6038 ត្រូវបានចៅក្រមស៊ើបសួរប្រគល់ឱ្យទៅម្ចាស់ដើមវិញ តាមដីកាសម្រេចលេខ៤៩៤“ខ”ព្រ.ទ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ គប្បីតុលាការមិនលើកយកមកសម្រេចទៀតទេ។

(២)-កាំបិតប៉ុងតោ ចំនួន០១(មួយ) ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

១៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវុធ បានប្តឹងទាមទារសំណងថ្លៃព្យាបាលរបួស ចំនួន២,000,000 (ម្ភៃលាន)រៀល និងសំណងជំងឺចិត្ត ចំនួន៤,000,000(បួនលាន)រៀល ពីជនជាប់ចោទឈ្មោះ [redacted] ចំរឿន គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ទៅលើជនជាប់ចោទខាងលើ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អាចឱ្យតុលាការលើកយកមកពិចារណាបាន។

១៦-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៧-សម្តីចុងក្រោយរបស់ជនជាប់ចោទ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស៖

១-១-ឈ្មោះ [redacted] រិទ្ធិស័ក្ត ភេទប្រុស កើតថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩(អាយុ១៤ឆ្នាំ) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១(មួយ)ឆ្នាំ តែទោសនេះអនុវត្តទោសពន្ធនាគារ១០(ដប់)ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា តាមបញ្ញត្តិមាត្រា១១៧,មាត្រា១១៨ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបុរីវ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១១ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

១-២-ឈ្មោះ [redacted] ចំរឿន ភេទប្រុស កើតឆ្នាំ២០០៤(អាយុ១៩ឆ្នាំ) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ តែទោសនេះអនុវត្តទោសពន្ធនាគារ១៨(ដប់ប្រាំបី)ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា តាមបញ្ញត្តិមាត្រា១១៧ និងមាត្រា១១៨ នៃក្រមព្រហ្មទណ្ឌ។

១-៣-ឈ្មោះ [redacted] វីន ភេទប្រុស កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៦(អាយុ១៧ឆ្នាំ) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់០១(មួយ)ឆ្នាំ តាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច មុខបុរីវ៉ូស ផ្លូវបេតុង ស្ថិតនៅភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ[redacted] ចំរឿន ភេទប្រុស អាយុ១៩ឆ្នាំ សងសំណងថ្លៃព្យាបាលរបួស ចំនួន៦,០០០,០០០៛ (ប្រាំមួយលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សារុធ។ ការទាមទារលើសពីនេះបដិសេធចោល។

៣-វត្ថុចាប់យក៖

៣-១-ម៉ូតូ០១គ្រឿង ម៉ាកHONDA DREAM C125 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1KC-0373(មិនប្រក្រតី) ខូចខាតក្បាំងខាងមុខ ក្បាំងចំហៀង កុងទ័រ ស្តុបខាងក្រោយ និងខូចផ្លាកលេខ ប្រគល់ឱ្យឈ្មោះ [redacted] ចំរឿន វិញ។

៣-២-ម៉ូតូ០១គ្រឿង ម៉ាក HONDA WAVE C100 ពណ៌ក្រហម ផ្លាកលេខ ក្រុងកែប 1A-0545 (មិនប្រក្រតី) ប្រគល់ឱ្យឈ្មោះ [redacted] វីន វិញ។

៣-៣-កាំបិតប៉ុងតោ ចំនួន០១(មួយ) ត្រូវរឹបអូស។

សាលក្រមនេះជំនុំជម្រះ ជាអសាធារណៈ នៅថ្ងៃទី០៩ និងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំរឿន, ឈ្មោះ [redacted] វីន និងឈ្មោះ [redacted] រិទ្ធិស័ក្ត, ចំពោះមុខមេធាវី និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤។ ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]



[redacted]

Scanned with CamScanner